# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ ខ្មែរកម្ពុជាក្រោមនិងរាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន

website : www.hoksavann.org

ថ្ងៃទី១៣ កុម្ភៈ ២០០៦



កម្ពុជាក្រោមនិងជនជាតិខ្មែរដែលរស់នៅលើទឹកដីនោះ គឺជាទឹកដីនិងជនជាតិរបស់រាជាណាចក្រកម្ពុជា បានត្រូវបារាំងអាណានិគមកាត់ឲ្យទៅប្រទេសវៀតណាម កាលពីថ្ងៃទី៤ មិថុនា ១៩៤៩ ។ កម្ពុជាក្រោមមានទំហំដី៦៨,៦០០គីឡូម៉ែត្រក្រឡា ប្រជាជនកាន់ព្រះពុទ្ធសាសនា មានវត្តជាងប្រាំរយ និងព្រះសង្ឃជាង២៥,០០០អង្គ ។ ចំនួនខេត្តមាន២១ខេត្ត ចំណែកជនជាតិខ្មែរដែលរស់នៅលើទឹកដីកំណើតរបស់ខ្លួននោះ រហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់មានជំរឿនជាថ្មីថាមានចំនួនប៉ុន្មានទេ ឯកសារខ្លះថា មានចំនួនរហូតដល់១១លាននាក់ ជិតស្មើនឹងប្រជាជនក្នុងរាជាណាចក្រកម្ពុជា ។ ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ត្រូវវៀតណាមអាណានិគមធ្វើទុក្ខបុកម្នេញបំបិទសិទ្ធិគ្រប់បែបយ៉ាង បងប្អូនខ្មែរកម្ពុជាក្រោមខ្លះទ្រាំទ្រមិនបាន ក៏រត់មករាជាណាចក្រកម្ពុជា ពឹងលើរាជរដ្ឋាភិបាលខ្មែរឲ្យជួយសង្គ្រោះខ្លួន ។

មកដល់រាជាណាចក្រកម្ពុជា បងប្អូនខ្មែរកម្ពុជាក្រោមបានខកចិត្ត ដោយរាជរដ្ឋាភិបាលខ្មែរធ្វើព្រងើយកន្តើយមិនយកចិត្តទុកដាក់ដោះស្រាយបញ្ហាដែលបងប្អូនកម្ពុជាក្រោមស្នើឲ្យជួយ ដូចបញ្ហាសុំចូលសញ្ជាតិ ត្រូវអាជ្ញាធរខ្មែរមិនអនុញ្ញាតឲ្យចូលឡើយ បើបងប្អូនខ្មែរកម្ពុជាក្រោមនៅតែនិយាយការពិតថា មានកំណើតនៅកម្ពុជាក្រោម ។ ផ្ទុយទៅវិញ ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវអាជ្ញាធរខ្មែរយកចិត្តទុកដាក់ជួយដោះស្រាយ ដូចជាក្រសួងមហាផ្ទៃខ្មែរអនុញ្ញាតឲ្យជនជាតិវៀតណាមបង្កើតសមាគម១៩ខេត្តនៅប្រទេសកម្ពុជា ដើម្បីសង្គ្រោះគ្នាគេរៀងរាល់ឆ្នាំ ។ ផ្ទុយពីបងប្អូនខ្មែរកម្ពុជាក្រោមនៅវៀតណាម អាជ្ញាធរវៀតណាម

មិនអនុញ្ញាតឲ្យខ្មែរបង្កើតសមាគមឡើយ ។ រាល់ពេលដែលវៀតណាមធ្វើបាបខ្មែរកម្ពុជាក្រោម មានចាប់ព្រះសង្ឃដាក់គុក រហូតព្រះសង្ឃខ្លះត្រូវសុគត ក៏គ្មានព្ររាជរដ្ឋាភិបាលខ្មែរស្រែកអំពាវនាវ ឲ្យអាជ្ញាធរវៀតណាមឈប់ប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សនេះឡើយ ។ មិនត្រឹមតែមិនជួយខ្មែរកម្ពុជាក្រោមប៉ុណ្ណោះទេ រាជរដ្ឋាភិបា-លខ្មែរ ដែលដឹកនាំដោយនាយករដ្ឋមន្ត្រីខ្មែរបច្ចុប្បន្ននេះ បានធ្វើតាមវៀតណាមបង្ខំឲ្យស្ថាប័នធំៗរបស់ខ្មែរ រដ្ឋសភា ព្រឹទ្ធសភា និងព្រះមហាក្សត្រ យល់ព្រមនិងចុះព្រះហត្ថលេខាលើសន្ធិសញ្ញាបំពេញបន្ថែមលើសន្ធិសញ្ញា ដែលមានភាពមិនស្មើគ្នា មិនស្របច្បាប់ឆ្នាំ១៩៨៥ ឲ្យស្របច្បាប់ ដើម្បីឲ្យទឹកដីកម្ពុជាក្រោមដាច់ចេញជាស្ថាពរពីកម្ពុជាកណ្តាល ដោយគ្មានការទាមទារផង ហើយឯកសារខ្លះបានពោលថា សន្ធិសញ្ញានេះបានធ្វើឲ្យខ្មែរបាត់បង់ដែនសមុទ្រនិងដីគោកអស់ជាច្រើនពាន់គីឡូម៉ែត្រក្រឡាផង ។ ទំរើធ្វើឲ្យស្របច្បាប់នូវសន្ធិសញ្ញាឆ្នាំ២០០៥នេះ ក៏ទុកដូចធ្វើឲ្យស្របច្បាប់នូវសន្ធិសញ្ញា៣ទៀតដែរគឺ ៖ ១- សន្ធិសញ្ញាសន្តិភាព«មិត្តភាពនិងសហប្រតិបត្តិការ»ចំនួន២៥ឆ្នាំ ហើយនិងបន្តជាស្វ័យប្រវត្តិ១០ឆ្នាំម្តងៗ ចុះថ្ងៃទី១២កុម្ភ:១៩៧៩, ២- កិច្ចព្រមព្រៀងអំពីទឹកសមុទ្រនិងសមុទ្រប្រវត្តិសាស្ត្រចុះថ្ងៃ៧កក្កដា១៩៨២, ៣- សន្ធិសញ្ញា«គោលការណ៍ដំណោះស្រាយព្រំដែននិងកិច្ចព្រមព្រៀងលើលក្ខន្តិក:ព្រំដែន» ចុះថ្ងៃទី២០កក្កដា១៩៨៣ និង៤- សន្ធិសញ្ញាស្តីអំពីការកំរិតព្រំដែន ចុះថ្ងៃទី២៧ធ្នូ១៩៨៥ ។ ឯកសារខ្លះពោលថា សន្ធិសញ្ញាឆ្នាំ១៩៨២ នាំឲ្យខ្មែរបាត់បង់កោះត្រល់និងកោះក្រចកសេះ គឺវៀតណាមកាត់យកសមុទ្រខ្មែរអស់៣០, ០០០គ.ម.២ និងសមុទ្រប្រវត្តិសាស្ត្រអស់១០,០០០គព្ស៊មព្ស៊២ទៀត ដែលត្រួតត្រាដោយប្រទេសទាំងពីរ ។ ចំណែកសន្ធិសញ្ញាឆ្នាំ១៩៨៥ នាំឲ្យខ្មែរបាត់បង់ដីគោកអ-ស់ជាច្រើនគីឡូម៉ែត្រ ដោយទាត់ចោលផែនទីបារាំង ហើយយកតាមផែនទីដែលវៀតណាមតាក់តែងថ្មី ។ បញ្ហាបាត់បង់ទឹកដីនេះពុំកើតមានឡើយ បើរាជរដ្ឋាភិបាលខ្មែរសុខចិត្តធ្វើតាមកិច្ចព្រមព្រៀងអន្តរជាតិនាក្រុងប៉ារីសឆ្នាំ១៩៩១ ដែលប្រកាសឲ្យលុបចោល នូវសន្ធិសញ្ញាដែលរំលោភលើប្រយោជន៍និងបូរណភាពទឹកដីខ្មែរ ។ អ្នកណាក៏ដឹងដែរថា បក្សប្រជាជនកម្ពុជាសព្វថ្ងៃនេះកើតពីវៀតណាម ហើយសព្វថ្ងៃនេះក៏វៀតណាមនៅពីក្រោយ ម្ល៉ោះហើយមិនហ៊ានធ្វើអ្វីឲ្យខុសពីបំណងវៀត-ណាមឡើយ សុខចិត្តចាប់ខ្មែរគ្នាឯងដាក់គុក ដើម្បីបំពេញចិត្តវៀតណាម ដូចចាប់សកម្មជនព្រំដែនពីរបីនាក់ដាក់គុកនៅព្រៃស លុះសន្ធិសញ្ញាបំពេញបន្ថែមនេះបានសំរេចហើយទើបដោះលែងវិញ ។

ដូចបានពោលមកហើយនេះបញ្ជាក់ថា រាជរដ្ឋាភិបាលខ្មែរមិនហ៊ានជួយបងប្អូនខ្មែរកម្ពុជាក្រោមទេ ព្រោះខ្លាចមានទំនាស់នឹងវៀតណាម នាំឲ្យវៀតណាមអាត់អន់ចិត្ត ដែលជាហេតុនាំឲ្យអំណាចរបស់ខ្លួនសព្វថ្ងៃនេះមានគ្រោះថ្នាក់ ព្រោះវៀតណាមកំពុងប្រឆាំងនឹងខ្មែរកម្ពុជាក្រោម ដែលព្យាយាមរើបំរះចេញពីអាណានិគមរបស់

ខ្លួន ។ ប៉ុន្តែរាជរដ្ឋាភិបាលខ្មែរគប្បីគិតថាត្រូវបំរើផលប្រយោជន៍ខ្មែរ ឬផលប្រយោជន៍វៀតណាម ។ មុនឡើងកាន់តំណែងគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលខ្មែរ បានធ្វើសច្ចាប្រណិធានចំពោះព្រះភ័ក្ត្រព្រះមហាក្សត្រនិងព្រះសង្ឃថា សុខចិត្តគោរពរដ្ឋធម្មនុញ្ញ បំរើផលប្រយោជន៍ខ្មែរ ជាពិសេសនៅមាត្រាទី៣៣នៃរដ្ឋធម្មនុញ្ញបានចែងថា «ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ» ។ ដូច្នេះបើមិនជួយបងប្អូនខ្មែរកម្ពុជាក្រោមដែលមានទុក្ខទេ ទុកជាក្បត់រដ្ឋធម្មនុញ្ញដែលខ្លួនបានធ្វើសច្ចាប្រណិធាន ។ ជាពិសេសមួយទៀត អំណាចរបស់រាជរដ្ឋាភិបាលខ្មែរសព្វថ្ងៃនេះ កើតពីសន្លឹកឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរ ដែលបោះជ្រើសរើសតំណាងរាស្ត្រ បង្កើតជាសភាជាតិ ហើយរដ្ឋសភាតែងតាំងរដ្ឋាភិបាលឲ្យដឹកនាំប្រទេស ។ ដូច្នេះត្រូវបំរើផលប្រយោជន៍ខ្មែរ ដើម្បីឲ្យខ្មែរបោះឆ្នោតឲ្យទៀត មិនត្រូវខ្លាចវៀតណាមឲ្យខូចផលប្រយោជន៍ខ្មែរឡើយ ។ បើមិនអាចជួយបងប្អូនខ្មែរកម្ពុជាក្រោមដោយចេញមុខទេ ក៏គួររាជរដ្ឋាភិបាលខ្មែរកុំយកជើងរាទឹក ព្រោះបងប្អូនខ្មែរកម្ពុជាក្រោមពេលនេះ ហាក់ដូចជាចុះទឹកក្រពើ ឡើងលើខ្លា ។៚